ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលារាជធានីភ្នំពេញ

លេខ: ៤៦ [illegible]

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១

## សេចក្តីជូនដំណឹង

## ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១១

អនុលោមតាមប្រកាសលេខ ៣៨៣ សហវ.អពដ.ប្រក ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១១ និងសេចក្តីជូនដំណឹងលេខ ០០៧ សហវ.អពដ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ ។ ដូចនេះសាលារាជធានីភ្នំពេញ សូមជូនដំណឹងដល់គ្រប់ក្រសួង មន្ទីរ អង្គភាព ក្រុមហ៊ុន និងប្រជាពលរដ្ឋដែលជាម្ចាស់យានយន្តគ្រប់ប្រភេទឲ្យបានជ្រាបថា ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ ត្រូវអនុវត្តចាប់ពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ រហូតដល់ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១ នៅតាមសាខាពន្ធដារខណ្ឌ និង ទីកន្លែង មួយចំនួនដូចខាងក្រោម ៖

I- ខណ្ឌឫស្សីកែវ

- នៅសាខាពន្ធដារខណ្ឌ ឫស្សីកែវ ផ្លូវជាតិលេខ ៥ សង្កាត់ ឫស្សីកែវ
- នៅអាគារ អតីតស្នាក់ការពន្ធដារខណ្ឌ ឫស្សីកែវ ផ្លូវជាតិលេខ៥ សង្កាត់ គីឡូម៉ែត្រលេខ៦
- នៅផ្លូវលេខ ១៩៨៦+ ១០១៩ សង្កាត់ភ្នំពេញថ្មី ខណ្ឌ សែនសុខ
- នៅផ្លូវ ២៧១ ទល់មុខផ្សារ ហេង លី សង្កាត់ទឹកថ្លា ខណ្ឌ សែនសុខ

II- ខណ្ឌដូនពេញ

- នៅសាខាពន្ធដារខណ្ឌដូនពេញ អាគារលេខ ១៦៦ វិថីខេមរៈភូមិន្ទ(ផ្លូវ១៣០) សង្កាត់ផ្សារកណ្តាល២
- នៅអាគារលេខ ២៥ បេ ផ្លូវ ២១៤ សង្កាត់ បឹងរាំង

III- ខណ្ឌ៧មករា

- នៅអាគារ អតីតស្នាក់ការពន្ធដារខណ្ឌ ៧មករា ផ្លូវលេខ ១០៥ សង្កាត់ បឹងព្រលឹត

IV- ខណ្ឌមានជ័យ

-នៅសាខាពន្ធដារខណ្ឌ អាគារលេខ ៣៨សេ ផ្លូវលេខ ៣៦១កែង៦៥២ សង្កាត់ច្បារអំពៅ១(ខាងត្បូងសាលាខណ្ឌមានជ័យ ប្រមាណ ២០០ម៉ែត្រ )

-នៅអាគារលេខ ១៧ (អតីតស្នាក់ការពន្ធដារខណ្ឌ )ផ្លូវជាតិលេខ១ សង្កាត់ច្បារអំពៅ២

V- ខណ្ឌចំការមន

-នៅសាខាពន្ធដារខណ្ឌចំការមនថ្មី អាគារលេខ ២៨ ផ្លូវលេខ ៤៨៨ សង្កាត់ ផ្សារដើមថ្កូវ

-នៅអាគារលេខ ៣៦៦(អតីតស្នាក់ការពន្ធដារខណ្ឌ) វិថីព្រះសីហនុ (ផ្លូវ ២៧៤ ) សង្កាត់ អូរឡាំពិក

VI- ខណ្ឌទួលគោក

-នៅសាខាពន្ធដារខណ្ឌទួលគោក អាគារលេខ ២៨ ផ្លូវលេខ ២៨៧ សង្កាត់ បឹងកក់ទី១

-នៅអាគារលេខ ២០២បេ(អតីតស្នាក់ការពន្ធដារខណ្ឌ)វិថីឧកញ៉ា ទេព ផន(១៨២)សង្កាត់ សង្កាត់ផ្សារដេប៉ូទី១



Downloaded From http://www.khmerlaws.com

VII- ខណ្ឌដង្កោ

-នៅសាខាពន្ធដារ ខណ្ឌ ដង្កោ អាគារលេខ ២៣៨ ផ្លូវលេខ២០០៧ (ខាងលិចឈាងខាងជើងស្ទួន) សង្កាត់កាកាប

-ទល់មុខសាលាខណ្ឌដង្កោ (អាគារអតីតស្នាក់ការពន្ធដារខណ្ឌ) ជាប់ផ្លូវសហព័ន្ធរុស្ស៊ី (ផ្លូវជាតិលេខ ៤) សង្កាត់កាកាប

-នៅមុខក្រុមហ៊ុន K.T.M.Co.Ltd រង្វង់មូលចោមចៅ (ផ្លូវជាតិលេខ៤) សង្កាត់ ចោមចៅ

-នៅមុខរោងចក្រ ហុងដា ផ្លូវចោមចៅ(វេងស្រេង) សង្កាត់ ចោមចៅ

-នៅមុខសាលាឆទាន ខាងត្បូងសាលាសង្កាត់ ដង្កោ ជាប់ផ្លូវចំការដូងទៅជើងឯក

ដើម្បីទទួលបាននូវការបង់ពន្ធត្រឹមត្រូវ និងជៀសវាងការក្លែងបន្លំពីសំណាក់ជនខិលខូច ដូចនេះ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងអស់ ត្រូវអញ្ជើញទៅបង់ពន្ធនៅកន្លែងដែលបានកំណត់ខាងលើ និងត្រូវបំពេញសំណុំបែបបទតាមការណែនាំរបស់មន្ត្រីពន្ធដារ ។ ចំពោះករណីមានមន្ត្រីពន្ធដារ ឬ ជនខិលខូចដែលឆ្លៀតឱកាសលួចប្រមូលពន្ធក្រៅទីតាំងដែលបានកំណត់ខាងលើ អាជ្ញាធរខណ្ឌ សង្កាត់ កម្លាំងនគរបាល និងកងរាជអាវុធហត្ថរៀបចំសំណុំឯកសារ និងរាយការណ៍មកសាលារាជធានីភ្នំពេញ ដើម្បីដោះស្រាយតាមច្បាប់ជាធរមាន ។

សាលារាជធានីភ្នំពេញមានជំនឿជឿជាក់ថា គ្រប់ក្រសួង មន្ទីរ អង្គភាព ក្រុមហ៊ុន និងប្រជាពលរដ្ឋ ដែលជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះទាំងអស់ នឹងយកចិត្តទុកដាក់បំពេញកាតព្វកិច្ចសារពើពន្ធបានល្អជាមិនខាន ។

អភិបាលរាជធានីភ្នំពេញ

កែប ជុតិមា

កន្លែងទទួល
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសាធារណៈការ និងដឹកជញ្ជូន
  "*ដើម្បីជូនជ្រាប*"
- គ្រប់មន្ទីរ អង្គភាពជុំវិញសាលារាជធានីភ្នំពេញ
- គ្រប់សាលាខណ្ឌ
  "*ដើម្បីអនុវត្ត*"
- គ្រប់ស្ថានីយ៍វិទ្យុ-ទូរទស្សន៍
  "*ដើម្បីជួយផ្សព្វផ្សាយ*"
- កាលប្បវត្តិ-ឯកសារ